**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈទន្តពេទ្យកម្ពុជា**

លេខ:...០០៥៤/១៩.......គ.ទ.ជ

# សេចក្តីសម្រេច

## ស្តីពី

## និយាមអប្បបរមានៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត

## សម្រាប់អ្នកប្រកបវិជ្ជាជីវៈទន្តសាស្ត្រ

---

## គណៈទន្តពេទ្យកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០៦) ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រម លេខ នស/រកម/១១០០/១០ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០០ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងលើការប្រកបវិជ្ជាជីវៈឯកជនក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ
- បានឃើញព្រះរាជក្រម នស/រកម/១១១៦/០១៤) ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៦ ប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងអ្នកប្រកបវិជ្ជាជីវៈវិស័យសុខាភិបាល
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៨០៥/៣៩៦ ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០០៥ ស្តីពីការបង្កើតគណៈទន្តពេទ្យកម្ពុជា
- បានឃើញអនុក្រឹត្យ លេខ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យ លេខ ១៥៦.អនក្រ.បក ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៩ ស្តីពី ក្រមសីលធម៌ទន្តពេទ្យ
- បានឃើញសេចក្តីសម្រេច លេខ០៧៦ អបស.អធម ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១៧ ស្តីពីការតែងតាំងគណៈកម្មការសម្របសម្រួលគណៈវិជ្ជាជីវៈសុខាភិបាល
- យោងតាមការចាំបាច់

# សម្រេច

## ផ្នែកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

សេចក្តីសម្រេចនេះមានគោលបំណងគ្រប់គ្រង និងជម្រុញការអនុវត្តច្បាប់ស្តីពី ការគ្រប់គ្រងអ្នកប្រកបវិជ្ជាជីវៈវិស័យសុខាភិបាល និងកំណត់និយាមអប្បបរមាដើម្បីស្នើសុំ និងបន្តអាជ្ញាបណ្ណវិជ្ជាជីវៈ។

**ប្រការ ២.-**

និយាមនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត មានវិសាលភាពអនុវត្តចំពោះអ្នកប្រកបវិជ្ជាជីវៈទន្តសាស្ត្រទាំងសាធារណៈ ឯកជន អង្គការនានា និងដៃគូអភិវឌ្ឍវិស័យសុខាភិបាល ទោះជាទទួល ឬមិនទទួលបានកម្រៃពីការងារនោះក៏ដោយ។

និយាមសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្តនេះ មិនអនុវត្តចំពោះអ្នកវិជ្ជាជីវៈដែលមិនប្រកបវិជ្ជាជីវៈទន្តសាស្ត្រនោះទេ។

**ប្រការ ៣.-**

ដើម្បីបំពេញតាមនិយាមនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត អ្នកប្រកបវិជ្ជាជីវៈជាជនជាតិខ្មែរដែលមានអាជ្ញាបណ្ណអ្នកប្រកបវិជ្ជាជីវៈទន្តសាស្ត្រ ត្រូវបំពេញសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្ត ឱ្យបានយ៉ាងតិច៦០(ហុកសិប)ពិន្ទុ រៀងរាល់វគ្គ៣ឆ្នាំ ។

ចំពោះអ្នកប្រកបវិជ្ជាជីវៈទន្តសាស្ត្រ ជាជនបរទេស ត្រូវបំពេញសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្ត យ៉ាងតិច២០(ម្ភៃ) ពិន្ទុ រៀងរាល់វគ្គ១ឆ្នាំ។

**ប្រការ ៤.-**

ក្នុងករណីអ្នកមានអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសុខាភិបាលលើសពីមួយ សាមីខ្លួនត្រូវបំពេញសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្ត ដែលតម្រូវដោយគណៈវិជ្ជាជីវៈសុខាភិបាលនីមួយៗ។

ចំពោះសកម្មភាពនៃការអភិវឌ្ឍវិជ្ជាជីវៈបន្តទាំងឡាយណាដែលពាក់ព័ន្ធទៅនឹងវិជ្ជាជីវៈលើសពីមួយ អ្នកប្រកបវិជ្ជាជីវៈអាចរាប់សកម្មភាពនោះជាកស្តុតាងនៃពិន្ទុអភិវឌ្ឍវិជ្ជាជីវៈបន្ត សម្រាប់គណៈវិជ្ជាជីវៈសុខាភិបាលនីមួយៗ។

**ប្រការ ៥.-**

**វាក្យសព្ទសំខាន់ៗដែលប្រើក្នុងសេចក្តីសម្រេចនេះមាននិយមន័យដូចតទៅ៖**

**ការអភិវឌ្ឍវិជ្ជាជីវៈបន្ត** សំដៅដល់ដំណើរការនៃការសិក្សាពេញមួយជីវិត ដែលមានគោលបំណងរក្សា និងលើកកម្ពស់នូវការអនុវត្តន៍របស់អ្នកប្រកបវិជ្ជាជីវៈសុខាភិបាល ក្នុងការពង្រីកសមត្ថភាពវិជ្ជាជីវៈ តាមរយៈការសិក្សាស្រាវជ្រាវជំនាញវិជ្ជាជីវៈ សន្និសីទ សិក្ខាសាលា ។ល។ ដើម្បីអភិវឌ្ឍសមត្ថភាពផ្ទាល់ខ្លួន ដែលចាំបាច់ក្នុងការប្រកបវិជ្ជាជីវៈ។

**ការប្រកបវិជ្ជាជីវៈ** សំដៅដល់រាល់តួនាទីដែលបុគ្គលម្នាក់ៗប្រើជំនាញ និងចំណេះដឹងជាអ្នកប្រកបវិជ្ជាជីវៈសុខាភិបាលក្នុងវិជ្ជាជីវៈរបស់ពួកគេ។ ការប្រកបវិជ្ជាជីវៈ មិនសំដៅតែការផ្តល់សេវាព្យាបាល ថែទាំ វេជ្ជសាស្ត្រ ជាមួយអតិថិជនដោយផ្ទាល់នោះទេ ដោយរាប់បញ្ចូលទាំងការងារគ្រប់គ្រងរដ្ឋបាល អប់រំ/បណ្តុះបណ្តាល សិក្សាស្រាវជ្រាវ ផ្តល់ប្រឹក្សាអភិវឌ្ឍគោលនយោបាយ ឬបទប្បញ្ញត្តិ និងតួនាទីផ្សេងៗទៀត ដែលប៉ះពាល់ដល់សុវត្ថិភាព ប្រសិទ្ធភាពនៃការផ្តល់សេវាតាមរយៈវិជ្ជាជីវៈនោះ ទោះជាបាន ឬមិនបានទទួលកម្រៃក៏ដោយ ។

**អ្នកវិជ្ជាជីវៈសុខាភិបាល** សំដៅដល់គ្រូពេទ្យ ទន្តពេទ្យ ឱសថការី គិលានុបដ្ឋាក ទន្តគិលានុបដ្ឋាក ឆ្មប ដែលទទួលបានការចុះបញ្ជិកាជាមួយគណៈវិជ្ជាជីវៈសុខាភិបាលពាក់ព័ន្ធ។

**អ្នកប្រកបវិជ្ជាជីវៈសុខាភិបាល** សំដៅដល់អ្នកវិជ្ជាជីវៈសុខាភិបាលដែលទទួលបានអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈ។

**អង្គភាព ឬដៃគូផ្តល់ការបណ្តុះបណ្តាលសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្តដែលគណៈវិជ្ជាជីវៈទទួលស្គាល់** គឺជាអង្គភាព ឬដៃគូជារូបវន្តបុគ្គល ឬនីតិបុគ្គលណាមួយដែលត្រូវបានទទួលស្គាល់ដោយក្រុមប្រឹក្សាវិជ្ជាជីវៈ ថាបានបំពេញតាមបទដ្ឋានតម្រូវសម្រាប់ការផ្តល់នូវសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្ត ដែលមានគុណភាពដល់អ្នកប្រកបវិជ្ជាជីវៈសុខាភិបាល។ អង្គភាព និងដៃគូផ្តល់ការបណ្តុះបណ្តាលសម្រាប់ការ**អភិវឌ្ឍវិជ្ជាជីវៈបន្ត** ដែលគណៈវិជ្ជាជីវៈទទួលស្គាល់ អាចផ្តល់នូវសកម្មភាពវិជ្ជាជីវៈជាក់លាក់ ឬអន្តរវិជ្ជាជីវៈនៃសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្ត ឬទាំងពីរ។

## ផ្នែកទី២

## បេសកកម្ម

**ប្រការ ៦.~**

អ្នកបញ្ចប់ការសិក្សាមិនលើសពី៣ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទបញ្ចប់ការសិក្សាដោយជោគជ័យនៃគុណវុឌ្ឍិ មិនតម្រូវឱ្យបំពេញតាមនិយាមនៃការអភិវឌ្ឍវិជ្ជាជីវៈបន្តនេះទេ នៅពេលដែលសាមីខ្លួនស្នើសុំចុះបញ្ជិកា និងសុំអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈលើកដំបូង។

**ប្រការ ៧.~**

អ្នកប្រកបវិជ្ជាជីវៈទន្តសាស្ត្រ ត្រូវស្នើសុំបន្តអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈយ៉ាងតិច៣(បី)ខែ មុនពេលអាជ្ញាបណ្ណអស់សុពលភាព។ នៅពេលស្នើសុំបន្តអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈ អ្នកប្រកបវិជ្ជាជីវៈត្រូវប្រកាស និងផ្តល់ឯកសារភស្តុតាងដែលបង្ហាញថា សាមីខ្លួនបានអនុវត្តតាមនិយាមអប្បបរមានៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត។

ក្នុងករណីដែលអ្នកប្រកបវិជ្ជាជីវៈទន្តសាស្ត្រ មិនបានបំពេញពិន្ទុគ្រប់ចំនួនតាមលក្ខខណ្ឌ គណៈទន្តពេទ្យកម្ពុជានឹងមិនបន្តអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈជូនឡើយ។

**ប្រការ ៨.~**

អ្នកប្រកបវិជ្ជាជីវៈទន្តសាស្ត្រ ត្រូវរក្សាទុកនូវឯកសារកំណត់ត្រានៃសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្តរបស់ខ្លួន យ៉ាងហោចណាស់បានរយៈពេល៣(បី)ឆ្នាំ។

**ប្រការ ៩.~**

គណៈទន្តពេទ្យកម្ពុជា រក្សាទុកកំណត់ត្រារបស់អ្នកប្រកបវិជ្ជាជីវៈទន្តសាស្ត្រ ដែលបានត្រួតពិនិត្យរួច សម្រាប់ការបន្តអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈ ឬការធ្វើសវនកម្ម និងបញ្ជីអង្គភាព ឬដៃគូផ្តល់ការបណ្តុះបណ្តាលសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្ត ដែលគណៈទទួលស្គាល់ និងកម្មវិធី ឬវគ្គបណ្តុះបណ្តាលដែលបានអនុម័តដោយគណៈទន្តពេទ្យកម្ពុជា។

**ប្រការ ១០.~**

ការអនុលោមតាមនិយាមសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្ត គណៈទន្តពេទ្យអាចធ្វើសវនកម្ម បានគ្រប់ពេល ឬនៅពេលទទួលបានបណ្តឹងដែលពាក់ព័ន្ធនឹងនីតិសម្បទា ឬកំហុសឆ្គងក្នុងការប្រកបវិជ្ជាជីវៈទន្តសាស្ត្រ។

**ប្រការ ១១.-**

គណៈទន្តពេទ្យកម្ពុជា កំណត់លក្ខខណ្ឌ និងដំណើរការដាក់លាក់នៃការស្នើសុំ ដើម្បីទទួលស្គាល់ជាអង្គភាព ឬដៃគូ ផ្តល់ការបណ្តុះបណ្តាលសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្តទាំងជាតិ និងអន្តរជាតិ ព្រមទាំងការផ្តល់ពិន្ទុសម្រាប់សកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្ត ។

**ប្រការ ១២.-**

ករណីអ្នកប្រកបវិជ្ជាជីវៈទន្តសាស្ត្រ មិនបានបំពេញតាមនិយាមអប្បបរមានៃការបណ្តុះបណ្តាលវិជ្ជាជីវៈបន្ត ចាត់ទុកជាមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការប្រកបវិជ្ជាជីវៈទន្តសាស្ត្រទេ។

**ប្រការ ១៣.-**

គណៈទន្តពេទ្យកម្ពុជា អាចដាក់ទណ្ឌកម្មខាងវិន័យមួយ ឬច្រើន យោងតាមមាត្រា១៥ នៃច្បាប់ស្តីពីការគ្រប់គ្រងអ្នកប្រកបវិជ្ជាជីវៈវិស័យសុខាភិបាល ក្នុងករណីអ្នកប្រកបវិជ្ជាជីវៈណាម្នាក់មិនបានបំពេញតាមនិយាមនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត។

**ប្រការ ១៤.-**

គណៈទន្តពេទ្យកម្ពុជា ជាអ្នករៀបចំ៖

- គោលការណ៍ណែនាំស្តីពីការអភិវឌ្ឍវិជ្ជាជីវៈបន្ត សម្រាប់អ្នកប្រកបវិជ្ជាជីវៈទន្តសាស្ត្រ
- គោលការណ៍ណែនាំសម្រាប់អង្គភាព ឬដៃគូផ្តល់ការបណ្តុះបណ្តាលសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្ត
- សាលាកបត្រព័ត៌មាន

ការអភិវឌ្ឍវិជ្ជាជីវៈបន្ត ជាផ្នែកមួយនៃការបន្តអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈរៀងរាល់៣(បី)ឆ្នាំម្តង សម្រាប់អ្នកប្រកបវិជ្ជាជីវៈទន្តសាស្ត្រ។

## ផ្នែកទី៣

## អវសានប្បញ្ញត្តិ

**ប្រការ ១៥.-**

សេចក្តីសម្រេចទាំងឡាយណា ដែលផ្ទុយសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍។

សេចក្តីសម្រេចនេះ ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ

ថ្ងៃពុធ ១៤រោច ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ,ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៩

**ឧ.ក្រុមប្រឹក្សាគណៈទន្តពេទ្យជាតិ**

**ប្រធាន**

DENTAL COUNCIL OF CAMBODIA

**ទន្តបណ្ឌិត.សុខុម រិទ្ធីវុធ**

ចម្លងជូន

- គណៈកម្មការសម្របសម្រួលគណៈវិជ្ជាជីវៈសុខាភិបាល
- គណៈទន្តពេទ្យរាជធានី ខេត្ត
- មន្ទីរពេទ្យជាតិ មជ្ឈមណ្ឌលជាតិ
- មន្ទីរសុខាភិបាលរាជធានី ខេត្ត
- គ្រប់សាកលវិទ្យាល័យទាំងសាធារណៈ និងឯកជន
- សមាគមវិជ្ជាជីវៈទន្តសាស្ត្រ
- ឯកសារកាលប្បវត្តិ